# អនុស្សរណៈនៃការយោគយល់គ្នា
# រវាង
# ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា
# និង
# ក្រសួងការងារ ជនពិការ និងសង្គមកិច្ចនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

## ស្តីពី
## កិច្ចសហប្រតិបត្តិការលើវិស័យការងារ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការងារ ជនពិការ និងសង្គមកិច្ច នៃសាធារណរដ្ឋសង្គមនិយមវៀតណាម (ចាប់ពីពេលនេះតទៅ ហៅរួមគ្នាថា ភាគីទាំងពីរ និងហៅដាច់ពីគ្នាថា ភាគី)

-ដោយគោរពតាមគោលការណ៍សមធម៌ និងអត្ថប្រយោជន៍ទៅវិញទៅមក

-ដោយត្រូវការបង្កើត និងពង្រឹងទំនាក់ទំនងដ៏ល្អប្រពៃរវាងភាគីទាំងពីរ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ ដើម្បីផលប្រយោជន៍ជាតិ ក្នុងការពង្រឹងកំណើនសេដ្ឋកិច្ចរបស់ប្រទេសទាំងពីរ

-ដោយចែករំលែកបំណងប្រាថ្នារួម ដើម្បីលើកកម្ពស់គោលនយោបាយ និងទម្លាប់នៃការអនុវត្តដ៏ល្អប្រសើរនៃវិស័យការងារ និងលើកកម្ពស់សមត្ថភាព និងលទ្ធភាពរបស់ប្រទេសទាំងពីរ ក្នុងការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ ពង្រឹងជំនាញហត្ថពលកម្ម លើកកម្ពស់សន្តិសុខសង្គម គ្រប់គ្រងទេសន្តរប្រវេសន៍ការងារប្រកបដោយប្រសិទ្ធភាព និងការបង្ការក៏ដូចជាការប្រយុទ្ធប្រឆាំងការជួញដូរកម្លាំងពលកម្មរវាងប្រទេសទាំងពីរ។

បានឯកភាពគ្នាដូចតទៅ៖

### ប្រការ ១

សម្រាប់គោលបំណងរបស់អនុស្សរណៈនៃការយោគយល់គ្នានេះ (ចាប់ពីពេលនេះតទៅ ហៅថា **អនុស្សរណៈ**) អាជ្ញាធរមានសមត្ថកិច្ចគឺ៖

ក. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាតំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

ខ. ក្រសួងការងារ ជនពិការ និងសង្គមកិច្ច ជាតំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

### ប្រការ ២

ភាគីទាំងពីរត្រូវធ្វើការរួមគ្នា ឆ្ពោះទៅសម្រេចឱ្យបាននូវការលើកទឹកចិត្ត ដល់កិច្ចសហប្រតិបត្តិការបច្ចេកទេសរវាងប្រទេសទាំងពីរនៅក្នុងវិស័យការងារ ដូចតទៅ៖

ក. ការផ្លាស់ប្តូរប្រព័ន្ធកម្មវិធី ការសិក្សា ជំនាញឯកទេស ការស្រាវជ្រាវ ការសិក្សា និងព័ត៌មានពាក់ព័ន្ធវិស័យនានា រួមទាំង (តែមិនកំណត់ត្រឹម) ការសិក្សាប្រៀបធៀបលើវិស័យការងារមុខរបរ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋបាលការងារ ដូចជា ការចរចាជាសមូហភាព ការដាក់ឱ្យអនុវត្ត និងការអនុវត្តច្បាប់ ការដោះស្រាយវិវាទការងារ សន្តិសុខសង្គម ការគាំពារពលកម្មសេរីភាពអង្គការវិជ្ជាជីវៈ សុខភាពនិងសុវត្ថិភាពការងារ ការគ្រប់គ្រងហត្ថពលកម្មបរទេស និងការផ្លាស់ប្តូរព័ត៌មានទៅលើការពង្រឹងផលិតភាពការងារ។

ខ. ការលើកទឹកចិត្តការផ្លាស់ប្តូរទស្សនៈកិច្ចរវាងមន្ត្រីទទួលបន្ទុក និងមន្ត្រីជំនាញ។

គ. ការគ្រប់គ្រងទេសន្តរប្រវេសន៍ការងាររវាងប្រទេសទាំងពីរ។

ឃ.ការផ្លាស់ប្តូរព័ត៌មាន ដើម្បីទប់ស្កាត់ការជ្រើសរើស និងប្រើប្រាស់ពលករខុសច្បាប់ក៏ដូចជាការបង្ការ និងប្រយុទ្ធប្រឆាំងការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការជួញដូរមនុស្ស។

ង. ផ្នែកផ្សេងទៀត នៃកិច្ចសហប្រតិបត្តិការដែលភាគីទាំងពីរ បានព្រមព្រៀងគ្នាលើវិស័យការងារ។

## ប្រការ ៣

ភាគីទាំងពីរត្រូវសហការគ្នាក្នុងការអភិវឌ្ឍមុខជំនាញ ចំណេះដឹង និងការចែករំលែកបច្ចេកទេស ដើម្បីបង្កើនសមត្ថភាពជំនាញហត្ថពលកម្ម និងពង្រឹងផលិតភាពការងារ។

## ប្រការ ៤

សកម្មភាពដែលបានចែងក្នុងប្រការ ២ និងប្រការ ៣ ត្រូវបានអនុវត្តតាមរយៈមធ្យោបាយផ្សេងៗ ដូចជា ការផ្លាស់ប្តូរបទពិសោធន៍ក្នុងការអនុវត្តល្អប្រសើរ ព័ត៌មាន ឯកសារនិងអ្នកជំនាញ គម្រោងរួមគ្នា សិក្ខាសាលា និងការពិភាក្សា។

ការរៀបចំសកម្មភាពអនុវត្ត ត្រូវតែមានការឯកភាពគ្នារវាងភាគីទាំងពីរ ផ្អែកលើផលប្រយោជន៍ជាតិ និងធនធានដែលភាគីទាំងពីរមាន និងដោយឈរលើមូលដ្ឋាននៃការអនុវត្តតាមករណីនីមួយៗ។

ភាគីទាំងពីរអាចឯកភាពគ្នា ដើម្បីបង្កើតកិច្ចព្រមព្រៀងដាច់ដោយឡែក សម្រាប់វិស័យជាក់លាក់ណាមួយសម្រាប់សកម្មភាពដែលមានចែងក្នុងប្រការ ២ និងប្រការ ៣។

## ប្រការ ៥

ភាគីទាំងពីរឯកភាពគ្នាដើម្បីសហប្រតិបត្តិការលើការគ្រប់គ្រងពលករទេសន្តរប្រវេសន៍ដែលបានធ្វើចំណាកស្រុកមកធ្វើការទៅវិញទៅមករវាងប្រទេសទាំងពីរ។ កិច្ចសហប្រតិបត្តិការនឹងអនុវត្តតាមរយៈការផ្លាស់ប្តូរព័ត៌មានជាប្រចាំស្តីពីស្ថានភាពវិស័យការងារ នៃប្រទេសទាំងពីរ ដែលកំពុងបម្រើការងារលើទឹកដីនៃប្រទេសមួយទៀត។

ភាគីទាំងពីរនឹងសម្រួលដល់ពលករតាមព្រំដែន ក្នុងការដាក់ពាក្យស្នើសុំឯកសារធ្វើការស្របច្បាប់ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិនានា ព្រមទាំងបង្កនូវលក្ខខណ្ឌងាយស្រួលដល់ពលករដែលទទួលបានឯកសារធ្វើការស្របច្បាប់ ដើម្បីអាចបន្តការស្នាក់នៅ និងធ្វើការស្របច្បាប់។

## ប្រការ ៦

អាជ្ញាធរមានសមត្ថកិច្ចនៃភាគីនីមួយៗត្រូវចាត់តាំងជនបង្គោលថ្នាក់ជាតិកម្រិតមន្ត្រីជាន់ខ្ពស់ ដើម្បីសម្របសម្រួលការទំនាក់ទំនងរវាងភាគីទាំងពីរ។

## ប្រការ ៧

ដើម្បីគាំទ្រការអនុវត្ត **អនុស្សរណៈ** នេះ អាជ្ញាធរមានសមត្ថកិច្ចនៃភាគីទាំងពីរត្រូវចាត់តាំងមន្ត្រីមួយចំនួន ជាក្រុមការងារបច្ចេកទេសនៃភាគីនីមួយៗ។ តាមរយៈការពិគ្រោះយោបល់ជាមួយភាគីនីមួយៗក្រុមការងារបច្ចេកទេស ដែលត្រូវបានចាត់តាំងស្របទៅតាមប្រការនេះអាចសិក្សា ជួយជ្រោមជ្រែង តាមដាន និងផ្តល់យោបល់លើដំណើរការ និងនីតិវិធីនៃការអនុវត្ត **អនុស្សរណៈ** នេះ។

## ប្រការ ៨

ភាគីនីមួយៗត្រូវទទួលបន្ទុកលើចំណាយសម្រាប់ការធ្វើដំណើរ ការស្នាក់នៅ និងហូបចុកសម្រាប់គណៈប្រតិភូ និងបុគ្គលិករបស់ខ្លួននៅក្នុងអំឡុងពេលអនុវត្ត **អនុស្សរណៈ** នេះ រួមទាំងកិច្ចប្រជុំក្រុមការងារបច្ចេកទេស។

ភាគីម្ចាស់ផ្ទះ ត្រូវសម្របសម្រួលក្នុងការធ្វើដំណើរក្នុងស្រុក សម្រាប់គណៈប្រតិភូធ្វើទស្សនកិច្ច និងសម្រាប់ភស្តុភា និងចំណាយក្នុងការរៀបចំកិច្ចប្រជុំដែលពាក់ព័ន្ធនឹងការអនុវត្ត **អនុស្សរណៈ** នេះ។

## ប្រការ ៩

ការខ្វែងគំនិតទាំងឡាយដែលកើតចេញពីការបកស្រាយ ឬការអនុវត្ត **អនុស្សរណៈ** នេះត្រូវដោះស្រាយដោយមិត្តភាព តាមរយៈការចរចា ឬការពិគ្រោះយោបល់រវាងភាគីទាំងពីរ។

## ប្រការ ១០

**អនុស្សរណៈ** នេះត្រូវចូលជាធរមាន ចាប់ពីថ្ងៃដែលភាគីទាំងពីរចុះហត្ថលេខា។

**អនុស្សរណៈ** នេះត្រូវមានសុពលភាពរយៈពេល៥ (ប្រាំ) ឆ្នាំ និងអាចពន្យាសុពលភាពតាមការព្រមព្រៀងគ្នារវាងភាគីទាំងពីរ។ ទោះជាយ៉ាងនេះក្តី **អនុស្សរណៈ** នេះអាចត្រូវបានព្យួរ ឬបញ្ចប់ដោយភាគីណាមួយ ប្រសិនបើមានមូលហេតុត្រឹមត្រូវ ហើយការបញ្ចប់នោះត្រូវមានប្រសិទ្ធភាពបន្ទាប់ពី ៦០(ហុកសិប) ថ្ងៃ នៃកាលបរិច្ឆេទដែលភាគីណាមួយបានស្នើសុំបញ្ចប់ដោយជូនដំណឹងជាលាយលក្ខអក្សរទៅភាគីម្ខាងទៀត។

**អនុស្សរណៈ** នេះនៅតែមានប្រសិទ្ធភាព ក្នុងអំឡុងពេលនៃដំណើរការស្នើសុំបន្តសុពលភាព លើកលែងតែភាគីទាំងពីរទាមទារបញ្ចប់។

ការធ្វើវិសោធនកម្មណាមួយនៃ **អនុស្សរណៈ** នេះ អាចធ្វើទៅបានអាស្រ័យដោយមានការឯកភាពគ្នាតាមផ្លូវការទូត។

## ប្រការ ១១

ការបញ្ចប់ **អនុស្សរណៈ** នេះ មិនមានឥទ្ធិពលលើសុពលភាព និងរយៈពេលនៃការអនុវត្តផែនការសកម្មភាព គម្រោង និងកម្មវិធីដែលកំពុងដំណើរការ រហូតដល់បានបញ្ចប់គម្រោង និងកម្មវិធីទាំងឡាយនោះ។

ជាសក្ខីភាព ភាគីហត្ថលេខី ដែលបានទទួលសិទ្ធិពេញលេញពីរដ្ឋាភិបាលនៃប្រទេសរៀងៗខ្លួនបានចុះហត្ថលេខាលើ **អនុស្សរណៈ**។

ធ្វើនៅទីក្រុងហាណូយ ថ្ងៃទី២២ ខែមីនា ឆ្នាំ ២០១៧ ជាលាយលក្ខណ៍អក្សរ ជាបីច្បាប់ ជាភាសាខ្មែរ វៀតណាម និងអង់គ្លេស អត្ថបទនីមួយៗមានតម្លៃស្មើៗគ្នា។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាឯកសារគោល។

| | |
|---|---|
| **តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា** | **តំណាងក្រសួងការងារ ជនពិការ និងសង្គមកិច្ច នៃសាធារណរដ្ឋសង្គមនិយមវៀតណាម** |
| **អ៊ិត សំហេង** | **DAO NGOC DUNG** |
| រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | រដ្ឋមន្ត្រីក្រសួងការងារ ជនពិការ និងសង្គមកិច្ច |